ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

...ណុំរឿងសភាព្រហ្មទណ្ឌ

លេខ: ២៦៥

...ថ្ងៃទី ២០-៣-២០១២

សាលដីកា

លេខ: ១០៧ក្រ‖

...ថ្ងៃទី ២៦-១១-២០១២

# គាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ៨-២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ២៦-១១-២០១២ ដោយមានសមាសភាពដូចខាងក្រោម :

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

ឯកឧត្តម [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជី</u>

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ២៦៥ ចុះថ្ងៃទី ២០-៣-២០១២

រវាង :

-ជនជាប់ចោទឈ្មោះ [redacted] ហួង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិកណ្តាលជ្រុំ ឃុំកណ្តាលជ្រុំ ស្រុកពញាក្រែក ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិ [redacted] ស្រុក [redacted] សាសនាព្រះពុទ្ធ មុខរបរអ្នកបើកបររថយន្តភ្នំពេញសូរិយាដឹកអ្នកដំណើរ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ។

*<u>ជាប់ចោទពីបទ</u>* : បើកបរបង្កអោយស្លាប់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិព្រៃកោះ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ តំណាងអោយក្រុមហ៊ុនធីបកូអេសហ្វល(ខេមបូឌា)លីមីធីត មានអាស័យដ្ឋានបច្ចុប្បន្ននៅ [redacted] ។





Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិ អោយក្រុមហ៊ុនជាតិធានារ៉ាប់រងកាមិនកូ ។

-ជនរងគ្រោះឈ្មោះ [redacted]សាំង ភេទប្រុស កើតថ្ងៃទី ១០ ខែតុលា ឆ្នាំ១៩៧៥ នៅភូមិអណ្តូងស៊ីតែ ឃុំថ្លាប្រជុំ ស្រុកកោះអណ្តែត ខេត្តតាកែវ ឪពុកឈ្មោះ [redacted]ខឹម ម្តាយឈ្មោះ [redacted]ចាន់ មានមុខរបរជាអ្នកបើកបរអោយក្រុមហ៊ុនធីបកូអេសហ្វ (ខេមបូឌា) លីមីធីត (បានទទួលមរណៈភាព) តំណាងអយ្យការបានសម្រេចលើកបណ្តឹងអាជ្ញា ។

-ជនរងគ្រោះឈ្មោះ [redacted]វី ភេទប្រុស កើតនៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៨៨ នៅភូមិពោធិ៍មង្គល ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] វ៉ន់ ម្តាយឈ្មោះ [redacted]លី មានមុខរបរជាព្រូឡានរបស់ក្រុមហ៊ុនធីបកូ អេសហ្វល (ខេមបូឌា) លីមីធីត (បានទទួលមរណៈភាព) ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ១៣ និង៥៥នាទី នៅចំណុចស្ពានថ្មស្វាយទង ស្ថិតនៅក្នុងភូមិព្រៃកោះ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានករណីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងដែលបង្កឡើងរវាងរថយន្តភ្នំពេញសូរិយាដឹកអ្នកដំណើរ និងក្រុមហ៊ុនធីបកូអេសហ្វល(ខេមបូឌា) លីមីធីត (រថយន្តស៊ីទែន) ។ ដោយរថយន្តស៊ីទែនបានបើកបរមកដល់ចំណុចកើតហេតុ ហើយវេចង្កូតចុះឡើង ធ្វើអោយបុកទៅលើរថយន្តភ្នំពេញសុរិយា ដឹកអ្នកដំណើរផ្នែកខាងឆ្វេងត្រង់កន្លែងអ្នកបើកបរឈ្មោះ [redacted] ហួង ជាតៃកុងឡានបណ្តាលអោយរងរបួសជាទម្ងន់ ហើយអ្នកដែលរួមដំណើរនៅលើរថយន្តក្រុងនោះក៏រងរបួសមួយចំនួនដែរ ។ ចំណែកអ្នកបើកបររថយន្តស៊ីទែនឈ្មោះ [redacted]សាំង វិញបន្ទាប់ពីបើកបរបង្កហេតុរួចហើយក៏រងរបួសធ្ងន់ និងស្លាប់នៅនឹងកន្លែងកើតហេតុជាមួយព្រូឡានឈ្មោះ[redacted]វី តែម្តង ។ បន្ទាប់មកទើបសមត្ថកិច្ចបានមកដល់កន្លែងកើតហេតុ បានរៀបចំកសាងសំណុំរឿងបញ្ជូន តាមនីតិវិធីមកតុលាការតែម្តង ។

-បានឃើញៈ សាលក្រមព្រហ្មទណ្ឌលេខ ៧១ (ក) ចុះថ្ងៃទី ២៣-១១-២០១១ បានសម្រេចសេចក្តីថា៖

១-អោយជនជាប់ចោទឈ្មោះ [redacted] ហួង ភេទប្រុស អាយុ៣៩ឆ្នាំ រួចផុតពីការចោទប្រកាន់ពីបទបើកបរបង្កអោយស្លាប់អ្នកដ៏ទៃដោយអចេតនា ប្រព្រឹត្តនៅភូមិព្រៃកោះ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

២-បង្គាប់អោយក្រុមហ៊ុនធីបកូ អេសហ្វល(ខេមបូឌា) លីមីធីត(TIPCO ASHALT CAMBODIA COMPANY LIMITED) ជាអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ទទួលរ៉ាប់រងសងសំណងចំនួន ១,៥០០០$(មួយម៉ឺនប្រាំបួនដុល្លាអាមេរិក) អោយទៅក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (កាមិកូ) ដែលមានមេធាវីឈ្មោះ [redacted]សុខចាន់ ជាមេធាវីតំណាងដោយអាណត្តិ សុំលើសពីនេះ បដិសេធចោល ដោយគិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហួង មេធាវីលោក [redacted]សុខចាន់ តំណាងដោយអាណត្តិអោយក្រុមហ៊ុនជាតិ



Scanned with CamScanner

ធានារ៉ាប់រងកាំមិក្រូ និងកំចាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិន តំណាងអោយក្រុមហ៊ុនធីបកូអេសហ្វូល(ខេមបូឌា)លីមីធីត បើកសិទ្ធិអោយប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ដោយគិតចាប់ពីថ្ងៃទទួលបានដំណឹងពីសាលក្រមនេះតទៅ ។

-បានឃើញ: របាយការណ៍រឿងចុះថ្ងៃទី ២៩-៦-២០១២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញ: សេចក្តីចម្លងបណ្តឹងតវ៉ាលេខ ០៣ ចុះថ្ងៃទី ៣០-១-២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជា សារិន សុំប្តឹង ឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ក" ចុះថ្ងៃទី ២៣-១១-២០១១ លើសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ហួង (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

-លោក [redacted] ប្វ៉ា មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី (វត្តមាន)

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ:

-ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានប្តឹងឧទ្ធរណ៍នឹងសាលក្រមដែលបានសម្រេច អោយរួចផុតពីបទចោទ តែទាក់ទងនឹងសំណងរដ្ឋប្បវេណី សុំអោយក្រុមប្រឹក្សាពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

-លោក [redacted] ប្វ៉ា និងលោក [redacted] សុខចាន់ មេធាវីការពារអោយក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជា បានសន្និដ្ឋានថា ក្រុមហ៊ុនធីបកូ អេសហ្វូល(ខេមបូឌា)លីមីធីត គឺជាអ្នកបង្កគ្រោះថ្នាក់ចរាចរណ៍នេះកើតឡើង ចំពោះសំណងគឺក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជា បានទូទាត់សំណងជូនទៅជនរងគ្រោះ ដែលបានជិះរថយន្តក្រុង និងបានសងសំណងទៅក្រុមហ៊ុនភ្នំពេញសូរិយារួចរាល់ហើយ ។ សូមក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមទុកជាបានការ ។

-ជនជាប់ចោទឈ្មោះ [redacted] ហួង បានសំណូមពរថា ខ្លួនសុំបញ្ចប់រឿងត្រឹមនេះ មិនអោយមានពាក់ព័ន្ធទៀតទេ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី ។

ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា ។

ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាឧទ្ធរណ៍

## យល់ឃើញថា:

១-បណ្តឹងឧទ្ធរណ៍លេខ ០៣ ចុះថ្ងៃទី ៣០-១-២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិន សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ក" ចុះថ្ងៃទី ២៣-១១-២០១១ លើសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍លើករឿងនេះ យកមកជំនុំជម្រះបានលើសំណង ។

២-ឈ្មោះ [redacted] សាំង គ្រាន់តែជាអ្នកបើកបររថយន្ត អោយក្រុមហ៊ុនតែប៉ុណ្ណោះ ហើយបើកបរក្នុងពេលបំពេញកិច្ចការងារ ។ តាមច្បាប់អ្នកទទួលខុសត្រូវសំណង ។



Scanned with CamScanner

៣-តាមការសន្និដ្ឋានរបស់លោកមេធាវីការពារ អោយក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជាថា ក្រុមហ៊ុនធានាបានសងសំណងដល់ជនរងគ្រោះរួចរាល់អស់ហើយ ហើយការដែលតុលាការ បង្គាប់ឲ្យក្រុមហ៊ុនធីក្កូអេសហ្វូល (ខេមបូឌា) លីមីធីត ជាអ្នកសងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងជាការត្រឹមត្រូវហើយ ពីព្រោះថាតាមចម្លើយសារភាពរបស់ជនជាប់ចោទនិងចម្លើយសាក្សីមានភាពស៊ីចង្វាក់។ ករណីគ្រោះថ្នាក់ចរាចរណ៍នេះបណ្តាលមកពីឈ្មោះ [redacted] សាំង ជាអ្នកបើកបររថយន្តក្រុមហ៊ុនដឹកសាំង(ឡានស៊ីទែន) បានបើកបរបង្ហូតមកបុករថយន្តដឹកអ្នកដំណើរភ្នំពេញសូរិយា បណ្តាលឲ្យអ្នកដំណើរ និងអ្នកបើកបរមានរបួសធ្ងន់ធ្ងរដោយក្រុមហ៊ុនធានារ៉ាប់រងបានជួសជុលសំណងរួចហើយ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ៧១ ក ចុះថ្ងៃទី ២៣-១១-២០១១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង មានលក្ខណៈត្រឹមត្រូវហើយគប្បីសាលាឧទ្ធរណ៍តំកល់សាលក្រមនេះទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍របស់លោក [redacted] សារិន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ទាក់ទងសំណងរដ្ឋប្បវេណី។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧១ ក ចុះថ្ងៃទី ២៣-១១-២០១១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ទុកជាបានការ។

៣-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ២៦-១១-២០១១ ចំពោះមុខជនជាប់ចោទមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹង និងតំណាងមុខដើមបណ្តឹង បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

<u>សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍អនុវត្តសាលដីកានេះអោយបានសម្រេចប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។</u>

**ក្រឡាបញ្ជី**
ហត្ថលេខា: [redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា: [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា: [redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី០... ខែ ៤ ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner